ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកំពង់ស្ពឺ
សំណុំរឿងព្រហ្មទណ្ឌលេខ: ៣៤២
ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០
សាលក្រមព្រហ្មទណ្ឌលេខ:៥៥២(ក)
ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២១

តាងនាមប្រជារាស្ត្រខ្មែរ

សាលាដំបូងខេត្តកំពង់ស្ពឺ បានបើកសវនាការជាសាធារណៈក្នុងសាលសវនាការ នៃសាលាដំបូងខេត្តកំពង់ស្ពឺ នៅថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០២០ វេលាម៉ោង ៩ និង០០ នាទីព្រឹក ដែលមានសមាសភាព៖

ចៅក្រមជំនុំជម្រះ

ឯកឧត្តម [redacted] ជាប្រធានសាលាដំបូងខេត្តកំពង់ស្ពឺ

តំណាងអយ្យការ

លោក [redacted] ជាព្រះរាជអាជ្ញារង អមសាលាដំបូងខេត្តកំពង់ស្ពឺ

ក្រឡាបញ្ជីសវនាការ

លោក [redacted] ជាក្រឡាបញ្ជីសាលាដំបូងខេត្តកំពង់ស្ពឺ

មេធាវី ឬ អ្នកការពារក្តី

លោក [redacted]
មេធាវីការពារសិទ្ធិ ដើមបណ្តឹងរដ្ឋប្បវេណីៗ
លោក [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

ដើម្បីជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលើជនជាប់ចោទ

-ឈ្មោះ [redacted] មុនីរតន៍ ភេទប្រុស អាយុ ៥៥ឆ្នាំ ជនជាតិខ្មែរ មុខរបរ ជាប្រធានក្រុមហ៊ុន កំរិតវប្បធម៌ថ្នាក់ទី១២ ទីកន្លែងកំណើត [redacted] ខេត្តកណ្តាល ទីលំនៅសព្វថ្ងៃផ្ទះលេខ០៧ ផ្លូវលេខ១០១៣ ភូមិបាយ៉ាប សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] យឹម (ស) ម្តាយឈ្មោះ [redacted] វណ្ណនី (រ) ប្រពន្ធឈ្មោះ [redacted] សុផារី មានកូន ០៤ នាក់ ទោសពីមុនគ្មាន។

(ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ៤៧៨ ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២០ និង ដីកាបង្គាប់ឲ្យដោះលែងលេខ ២៣ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២០)។

1 | *សាលក្រមព្រហ្មទណ្ឌលេខ៖.៥៥២ (ក) ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២១ ។*

-ត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យពីបទៈ ឆបោកដោយមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅភូមិបឹងធ្នង់ និង ភូមិព្រៃរំដួលខាងត្បូង ស្ថិតក្នុងឃុំបសេដ្ឋ ស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ កាលពីអំឡុងឆ្នាំ២០១៩ ដល់អំឡុងឆ្នាំ២០២០ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ៣៧៧ និងមាត្រា ៣៨០ នៃក្រមព្រហ្មទណ្ឌ។

-បានឃើញ ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ម៉ឺងឈឺ[redacted] MINGQI) ភេទស្រី អាយុ៥៧ឆ្នាំ ជនជាតិចិន សញ្ជាតិខ្មែរ មានអាសយដ្ឋានស្ថិតនៅផ្ទះលេខ០១ ផ្លូវលេខ៥៨P ភូមិដីថ្មី សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ។

.ដោយមានអ្នកបកប្រែភាសា ឈ្មោះ [redacted]សំរិទ្ធ ភេទប្រុស ។

-បានឃើញ ដីកាសន្និដ្ឋានស្តាពរលេខៈ ៧៩៨៧ អក ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកំពង់ស្ពឺ ។

-បានឃើញ ដីកាដំណោះស្រាយលេខៈ ១២៩៤ ដកដស ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តកំពង់ស្ពឺ ។

-បានឃើញ ដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខៈ ១៣៩៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២០ របស់ប្រធានសាលាដំបូងខេត្តកំពង់ស្ពឺ។

<u>ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ</u>

-កាលពីអំឡុងឆ្នាំ២០១៩ រហូតដល់ពេលនេះឈ្មោះ [redacted] ម៉ឺងឈឺ[redacted] MINGQI) បានស្គាល់ឈ្មោះ [redacted] XIAOYO ភេទស្រី ជនជាតិចិន (សៀងហៃ) ហើយឈ្មោះ[redacted] XIAOYO បានណែនាំឲ្យឈ្មោះ[redacted] ម៉ឺងឈឺ[redacted] MINGQI) ស្គាល់ឈ្មោះ [redacted]មុនីរតន៍។ ឈ្មោះ[redacted] XIAOYO បាននាំឈ្មោះ[redacted] ម៉ឺងឈឺ[redacted] MINGQI) ទៅជួបឈ្មោះ[redacted]មុនីរតន៍ ហើយក៏បានជួបឈ្មោះ[redacted] ម៉ឺងឈឺ[redacted] MINGQI) ជាមួយជំនួយការម្នាក់ឈ្មោះ [redacted] ធីតា ភេទស្រី។ ឈ្មោះ [redacted] មុនីរតន៍ បានអះអាងថា ខ្លួនមានដីជាកម្មសិទ្ធិស្របច្បាប់របស់ខ្លួនសម្រាប់លក់ទំហំ ៥៨ (ហាសិបប្រាំបី) ហិចតា ស្ថិតក្នុងភូមិរំដួលខាងត្បូង និងភូមិបឹងធ្នង់ ឃុំបសេដ្ឋ ស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ។ ដោយមានការជឿជាក់ឈ្មោះ[redacted] ម៉ឺងឈឺ[redacted] MINGQI) ក៏បានទិញដីពីឈ្មោះ [redacted] មុនីរតន៍ ដោយធ្វើកិច្ចសន្យាលក់-ទិញដីធ្លី ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៩ ដោយនៅក្នុងកិច្ចសន្យាបានបញ្ជាក់ថា ភាគី (ក)[redacted]មុនីរតន៍ ជាម្ចាស់ដី។ ក្រោយមកទើបអ្នកទិញឈ្មោះ [redacted] ម៉ឺងឈឺ[redacted] MINGQI) ដឹងថាឈ្មោះ[redacted] មុនីរតន៍ មិនមែនជាកម្មសិទ្ធិករនៃដីដែលយកមកលក់ឲ្យនោះទេ ។

<u>នាពេលសវនាការ</u>

-តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] មុនីរតន៍ បានឆ្លើយសារភាពថាៈ កាលពីអំឡុងខែតុលា ឆ្នាំ២០១៩ ខ្លួនបានស្គាល់ ដើមបណ្តឹងឈ្មោះ [redacted] ម៉ឺងឈឺ តាមរយៈជនជាតិចិន ឈ្មោះ

[redacted] XIAOYO *ភេទស្រី ដែលចេះភាសាខ្មែរ ហើយបានទំនាក់ទំនងខ្លួនឲ្យរៀបចំដីឲ្យគាត់ចំនួន ៥៨ហិចតា ស្ថិតក្នុងភូមិបឹងធ្នង់ និងភូមិព្រៃរំរួលខាងត្បូង ឃុំបសេដ្ឋ ស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ ដោយមានធ្វើកិច្ចសន្យាលក់ទិញដី ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៩ រវាងខ្លួន និងឈ្មោះ [redacted] ម៉ឹង ឈឺ ។ មុនពេលចុះកិច្ចសន្យា ៣ខែ ខ្លួនបានទិញដីពីប្រជាពលរដ្ឋបានចំនួន ៣២ហិចតា ដោយបានធ្វើកិច្ចសន្យាលក់ត្រឹមទទួលស្គាល់ពីអាជ្ញាធរភូមិ.ឃុំ ។*

ក្រោយមកឈ្មោះ [redacted] XIAOYU ភេទស្រី បានប្រាប់ខ្លួនថា ឈ្មោះ [redacted] ម៉ឹង ឈឺ លក់ទិញដីចំនួន ៥៨ ហិចតា ហើយខ្លួនបានទទួលព័ត៌មាន ខ្លួនក៏បានរកទិញដីប្រជាពលរដ្ឋក្បែរ ដីរបស់ខ្ញុំបាទឲ្យគ្រប់ចំនួន ៥៨ ហិចតា ដើម្បីលក់ឲ្យឈ្មោះ [redacted] ម៉ឹង ឈឺ។ ក្រោយពីប្រមូលទិញដី គ្រប់ចំនួន ៥៨ ហិចតា ខ្លួនក៏បានទំនាក់ទំនងឈ្មោះ [redacted] XIAOYU ភេទស្រី ឲ្យទំនាក់ទំនង ទៅឈ្មោះ [redacted] ម៉ឹង ឈឺ ដើម្បីមកទិញដីរបស់ខ្លួន និងបានធ្វើកិច្ចសន្យាទិញលក់ដីធ្វី ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ ២០១៩ ដោយត្រូវបង់ប្រាក់ជា ៤ដំណាក់កាល ។ មុនពេលធ្វើកិច្ចសន្យាខ្លួនបានទទួលប្រាក់ចំនួន ២០.០០០$ (ពីរម៉ឺនដុល្លា) អាមេរិក ពីឈ្មោះ [redacted] ម៉ឹង ឈឺ និងនៅក្នុងពេលធ្វើកិច្ចសន្យាខ្លួនបានទទួលប្រាក់ចំនួន ១៨០.០០០$ (ដប់ប្រាំបីម៉ឺន) ដុល្លាអាមេរិក ពីឈ្មោះ [redacted] ម៉ឹង ឈឺ ដើម្បីបង្គ្រប់ថ្លៃដីចំនួន ២០០.០០០$ (ម្ភៃម៉ឺន) ដុល្លាអាមេរិក។ ចំពោះប្រាក់ចំនួន ៦៥០.០០០$ (ហុកសិបប្រាំម៉ឺន) ដុល្លាអាមេរិក ដែលត្រូវបង់នៅថ្ងៃទី៣០ ខែ តុលា ឆ្នាំ២០១៩ គឺឈ្មោះ [redacted] ម៉ឹង ឈឺ បានបង់ជាច្រើនដងទើបគ្រប់ចំនួន ។

ចំពោះការទូទាត់ដីដំណាក់កាលទី២ លើទឹកប្រាក់ចំនួន ៨៥០.០០០$ (ប៉ែតសិបប្រាំម៉ឺន) ដុល្លាអាមេរិក ដែលត្រូវបង់នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៩ គឺឈ្មោះ [redacted] ម៉ឹង ឈឺ ក៏បានបង់ជាច្រើនដងទើបគ្រប់ចំនួនដូចគ្នាដែរ។ ហើយប្រាក់ដែលខ្ញុំបានទទួលទាំងអស់គឺចំនួន ១.៧០០.០០០$ (មួយលានចិតសិបម៉ឺន)ដុល្លាអាមេរិក ហើយប្រាក់ទាំងអស់ដែលខ្ញុំទទួលបាន គឺខ្ញុំបាទបានប្រគល់ឲ្យឈ្មោះ ហេង ធីតា អស់ចំនួន ៧០០.០០០$ (ចិតសិបម៉ឺន)ដុល្លាអាមេរិក ដើម្បីរៀបចំទិញដីនោះ។

ខ្លួនសូមបញ្ជាក់ថា ទាក់ទិននឹងការទិញលក់ដីខាងលើ ខ្ញុំបាទបានធ្វើការរៀបចំបំពេញបែបបទផ្ទេរកម្មសិទ្ធិកាន់កាប់ពីប្រជាពលរដ្ឋជាម្ចាស់ដីដើមមកឈ្មោះខ្ញុំបាទ ដោយមានការទទួលស្គាល់ពីអាជ្ញាធរឃុំបសេដ្ឋ ហើយខ្លួនក៏បានបំពេញបែបបទផ្ទេរសិទ្ធិលើដីខាងលើបន្តទៅឲ្យឈ្មោះ [redacted] ម៉ឹង ឈឺ រហូតបានបញ្ចប់ការបង់ពន្ធប្រថាប់ត្រានៅរដ្ឋបាលពន្ធដារលើផ្ទៃដីចំនួន ៥៨ ហិចតា រួចរាល់ហើយ តាមលិខិតបញ្ជាក់អំពីការបង់ពន្ធប្រថាប់ត្រាលើការផ្ទេរសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យលេខ៨២៨ អពដ.សខ.កស្ត ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២០ ប្រាក់ចំនួន ១៥.១២៣.០០០៛ (ដប់ប្រាំលានមួយរយម្ភៃបីពាន់)រៀល អគ្គនាយកដ្ឋានពន្ធដាសារខាខេត្តកំពង់ស្ពឺ។

ចំពោះការទូទាត់ដំណាក់កាលទី៣ ឈ្មោះ [redacted] ម៉ឺងឈឺ បានយកប្រាក់ចំនួន ៤០០.០០០$ (សែសិបម៉ឺនដុល្លា)អាមេរិក ទៅទូទាត់ជាមួយប្រជាពលរដ្ឋដោយខ្លួនឯង នៅថ្ងៃទី០៧ ថ្ងៃទី០៩ ថ្ងៃទី ១០ ខែមករា ឆ្នាំ២០២០ ដោយឈ្មោះ [redacted] ម៉ឺងឈឺ បានរៀបចំលិខិតប្រគល់ទទួលប្រាក់ ចុះថ្ងៃទី ០៧ ថ្ងៃទី០៩ ថ្ងៃទី១០ ខែមករា ឆ្នាំ២០២០ ឲ្យខ្លួនផ្តិតមេដៃជាអ្នកទទួលប្រាក់ ប៉ុន្តែខ្លួន មិនបាន ទទួលប្រាក់ចំនួនខាងលើឡើយ ដោយឈ្មោះ [redacted] ម៉ឺងឈឺ ជាអ្នកយកប្រាក់ប្រគល់ឲ្យ ប្រជា ពលរដ្ឋដែលជាម្ចាស់ដីជាក់ស្តែង។

ដែលចំណុចនេះបញ្ជាក់ថាឈ្មោះ [redacted] ម៉ឺងឈឺ គឺជាអ្នកទទួលអនុវត្តកាតព្វកិច្ចទូទាត់ប្រាក់ ជូនប្រជាពលរដ្ឋជំនួសខ្លួនវិញ ដោយសារតែឈ្មោះ [redacted] ម៉ឺងឈឺ មិនបានទូទាត់ប្រាក់ឲ្យប្រជា ពលរដ្ឋបន្តទៀត ទើបធ្វើឲ្យប្រជាពលរដ្ឋស្នើទៅអាជ្ញាធរ មូលដ្ឋាន ដើម្បីមោឃៈនូវលិខិតផ្ទេរសិទ្ធិ កាន់កាប់ដីដែលខ្លួនបានរៀបចំជូនទៅឈ្មោះ [redacted] ម៉ឺងឈឺ។

សូមបញ្ជាក់បន្ថែមថា ចំពោះលិខិតធានាអះអាងជាមួយប្រជាពលរដ្ឋជាម្ចាស់ដី ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៩ ខ្លួនមានកាតព្វកិច្ចទូទាត់ប្រាក់២០% ទៅប្រជាពលរដ្ឋ ក្នុងរយៈពេល ១០ថ្ងៃ គិត ចាប់ពីថ្ងៃផ្តិតមេដៃលើលិខិតនេះ ហើយប្រាក់បន្ថែម ២០% ទៀត ត្រូវទូទាត់ជូនម្ចាស់ដីក្នុងរយៈ ពេល ២០ថ្ងៃ ក្រោយពីពេលដែលលិខិតផ្ទេរសិទ្ធិត្រូវបានចុះហត្ថលេខារបស់លោកអភិបាលស្រុក។

ជាក់ស្តែងទឹកប្រាក់ចំនួន ៤០០.០០០$ (សែសិបម៉ឺន)ដុល្លាអាមេរិក ត្រូវបានទូទាត់ជូន ប្រជាពលរដ្ឋ ដោយឈ្មោះ [redacted] ម៉ឺងឈឺ កាលពីថ្ងៃទី០៧ ថ្ងៃទី០៩ និងថ្ងៃទី១០ ខែមករា ឆ្នាំ២០២០ រួចរាល់អស់ហើយ ដូចនេះចំពោះការទូទាត់ប្រាក់បន្ថែម ២០%ទៀត អាចត្រូវបានធ្វើឡើងលុះត្រា តែលិខិតផ្ទេរសិទ្ធិ ត្រូវបានចុះហត្ថលេខាដោយអាជ្ញាធររួលរាល់ ប៉ុន្តែបែរជាអាជ្ញាធរស្រុកបសេដ្ឋ ចេញលិខិតលេខ ០០៨/០២០ ស.ក.ជ.ណ ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២០ ដោយបានសម្រេចទុក ជាមោឃៈនូវលិខិតផ្ទេរសិទ្ធិ ដោយចោទប្រកាន់ថា ខ្លួនបានបំពានលើលិខិតអះអាង ចុះថ្ងៃទី២៥ ខែ ធ្នូ ឆ្នាំ២០១៩ ទៅវិញ។

បើពិនិត្យទៅលើលិខិតផ្ទេរសិទ្ធិកាន់កាប់ដីធ្លីពីឈ្មោះប្រជាពលរដ្ឋមកខ្លួនឈ្មោះ [redacted] មុនីរតន៍ សំណុំឯកសារផ្ទេរសិទ្ធិកាន់កាប់ដីឈ្មោះខ្លួនទៅឈ្មោះ [redacted] ម៉ឺងឈឺ និងលិខិតបង់ពន្ធប្រថាប់ត្រា បង្ហាញឲ្យឃើញច្បាស់ថា ខ្លួនពិតជាបានរៀបចំប្រមូលទិញដីប្រជាពលរដ្ឋទៅ តាមទំហំដែលបាន កំណត់ក្នុងកិច្ចសន្យាទិញលក់ និងផ្ទេរកម្មសិទ្ធិកាន់កាប់បន្តឲ្យឈ្មោះ [redacted] ម៉ឺងឈឺ ពិតមែន គឺខ្លួន មិនបានប្រើប្រាស់ឧបាយកលទុច្ចរិតណាមួយ ដើម្បីឆបោកប្រាក់ពីឈ្មោះ ហ៊ូក ម៉ឺងឈឺ នោះទេ។

សូមបញ្ជាក់បន្ថែមថា ទាក់ទិននឹងការប្រមូលទិញដីពីប្រជាពលរដ្ឋ ដែលមានទីតាំងដូច ខាងលើឈ្មោះ [redacted] ធីតា ភេទស្រី គឺជាអ្នកជានាអះអាងចំពោះខ្លួនក្នុងការប្រមូលទិញដីនេះ ហើយឈ្មោះ [redacted] ធីតា គឺជាអ្នកទទួលប្រាក់ផ្ទាល់ពីខ្លួន ដើម្បីយកទៅជូនប្រជាពលរដ្ឋនូវគ្រប់

ពេលវេលាៗ ឈ្មោះ [redacted] ធីតា កេទស្រី អាយុប្រហែល ៤០ឆ្នាំ ស្ថិតនៅក្នុងបុរីឡាយគង់ ភូមិម័ល សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ ។

ចំពោះដីចំនួន ៥៨ ហិកតា នោះខ្លួនបានផ្ទេរកម្មសិទ្ធិរួចរាល់អស់ហើយបែរជាឈ្មោះ [redacted] ម៉ឺងឈឺ ពុំព្រមប្រគល់ប្រាក់គ្រប់ចំនួនមកឲ្យខ្លួនទៅវិញ ប្រាក់ដែលនៅសល់ចំនួន ៤០.០០០០$ (សែសិបម៉ឺន) ដុល្លាអាមេរិក ទៀត តែសុំឲ្យភាគីតម្កល់ប្រាក់នៅធនាគារជាមុនសិន ហើយប្រសិនបើខ្លួនគ្មានដីទើបខ្លួនមានកំហុស ដោយខ្លួនជាភាគី(ក) នៅក្នុងកិច្ចសន្យា ដែលបានចែងស្រាប់ខ្លួនមានតួនាទី និងកាតព្វកិច្ចទាំងនោះ។

ដោយដីទាំងអស់នោះបានក្លាយជាកម្មសិទ្ធិរបស់ខ្លួនហើយ តែពុំទាន់បានកាត់ឈ្មោះ នៅឡើយទេ ដោយខ្លួនទុកលក់បន្ត (ប្ងង់ទន់) ដោយសារផុតពីការបង់ពន្ធ ជារឿងកិច្ចការផ្ទៃក្នុងរបស់ក្រុមហ៊ុន ខ្លួន ។ ខ្លួនបានទទួលប្រាក់ពីឈ្មោះ [redacted] ម៉ឺងឈឺ ចំនួន១៧០០០០$ ដប់ប្រាំពីរម៉ឺន) ដុល្លាអាមេរិក ហើយប្រាក់មួយចំនួនទៀតឈ្មោះ [redacted] ម៉ឺងឈឺ គាត់បានទៅប្រគល់ឲ្យប្រជាពលរដ្ឋដោយផ្ទាល់។ ដែលត្រង់នេះហើយឈ្មោះ [redacted] ម៉ឺងឈឺ ពុំព្រមបង់ប្រាក់មកឲ្យខ្លួនទើបមានប្រជាពលរដ្ឋ ផ្ទុះមានបញ្ហាទាំងនោះ ។

-តាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ម៉ឺងឈឺ [redacted] MINGQI) ដោយមានអ្នកបកប្រែឈ្មោះ [redacted] សំរិទ្ធ បានឆ្លើយថា៖ ខ្លួនជាជនជាតិចិន ដែលមានសញ្ជាតិខ្មែរ តាមច្បាប់ស្តីពីសញ្ជាតិ ហើយដែលបានបោះទុនវិនិយោគលើវិស័យរោងចក្រកាត់ដេរនៅរាជធានីភ្នំពេញ។ ខ្លួនបានស្គាល់ឈ្មោះ [redacted] XIAOYU កេទស្រី ជនជាតិចិន (សៀងហៃ) (មានអាសយដ្ឋានផ្ទះលេខ ៣៩A បុរីសំបូរមាស ផ្លូវលេខ២ សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ ទូរស័ព្ទលេខ ០៩២ ៨៣៣ ៥៨៨) ហើយឈ្មោះ [redacted] XIAOYU នេះបាននិយាយប្រាប់ខ្លួនថា ខ្លួនស្គាល់ជនជាតិខ្មែរម្នាក់ឈ្មោះ [redacted] មុនីរតន៍ ជាអ្នកធំ និងជាអ្នកជំនួញអចលនទ្រព្យដ៏ធំនៅខេត្តកំពង់ស្ពឺ ហើយបានណែនាំខ្លួនឲ្យទិញដីពីឈ្មោះ [redacted] មុនីរតន៍ ទៀតផង។ បន្ទាប់មកឈ្មោះ [redacted] XIAOYU បាននាំខ្លួនទៅជួបជាមួយឈ្មោះ [redacted] មុនីរតន៍ ពេលនោះឈ្មោះ [redacted] មុនីរតន៍ បានមកជួបខ្លួនជាមួយជំនួយការម្នាក់ឈ្មោះ [redacted] ធីតា កេទស្រី (មានអាសយដ្ឋានផ្ទះលេខ ១៤៥បេ ផ្លូវរថភ្លើង ភូមិ១៦ សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ទូរស័ព្ទលេខ ០៩៥. ៨៨០ ៨៨៨) ។ ក្នុងជំនួបនេះឈ្មោះ [redacted] មុនីរតន៍ បានអះអាងថា ខ្លួនជាអ្នកជំនួញអចលនទ្រព្យនៅខេត្តកំពង់ស្ពឺ ហើយមានដីរាប់រយហិកតា ជាកម្មសិទ្ធិរបស់ខ្លួនសម្រាប់លក់។ ស្របពេលជាមួយគ្នានោះ ឈ្មោះ [redacted] មុនីរតន៍ ក៏បានបង្ហាញខ្លួននូវឯកសារដី ទំហំ ៥៨ ហិកតា (គំនូសបង្ហាញទីតាំងដីទំហំ ៥៨ ហិកតា) ដែលឈ្មោះនេះអះអាងថា ជាកម្មសិទ្ធរបស់ខ្លួនមានទីតាំងស្ថិតនៅភូមិរំដួលខាងត្បូង ឃុំបសេដ្ឋ ស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ ហើយបានណែនាំខ្លួនឲ្យទិញដី ដោយអះអាងថាដីនេះនឹងចំណេញ

ច្រើននៅថ្ងៃក្រោយៗ មិនត្រឹមតែប៉ុណ្ណោះឈ្មោះ [redacted] មុនីរតន៍ ក៏បាននាំខ្លួនចុះទៅពិនិត្យ និងចង្អុលបង្ហាញទីតាំងដីថែមទៀតផង ដែលធ្វើឲ្យខ្លួនរឹតតែលង់ជឿថែមទៀតថា ដីទំហំ ៥៨ ហិកតា នេះជាកម្មសិទ្ធរបស់ឈ្មោះ [redacted] មុនីរតន៍ ពិតមែនៗ ដោយសារលង់ជឿតាមការអះអាង និងការជានាគ្រប់រូបភាពរបស់ឈ្មោះ [redacted] មុនីរតន៍ នេះហើយ ទើបធ្វើឲ្យខ្លួនសម្រេចចិត្តទិញដីទំហំ ៥៨ ហិកតា ពីឈ្មោះ [redacted] មុនីរតន៍ ដោយគិតថា ជាអ្នកធំ និងជាអ្នករកស៊ីដីធ្លីផងនោះ គឺមិនបោកប្រាស់ខ្លួនឡើយ។

បន្ទាប់មកនៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៩ ខ្លួនបានចុះកិច្ចសន្យាទិញលក់ដីជាមួយឈ្មោះ កែវ មុនីរតន៍ ដែលបានព្រមព្រៀងគ្នាទិញលក់ ក្នុងតម្លៃ ៥.៨៦ (ប្រាំ ចុច ប៉ែតសិបប្រាំមួយ) ដុល្លាអាមេរិក ក្នុងមួយម៉ែត្រក្រឡា ដែលមានតម្លៃសរុបចំនួន ៣.៤០០.០០០$ (បីលានបួនសែន)ដុល្លាអាមេរិកៗ នៅថ្ងៃចុះកិច្ចសន្យាខ្លួនក៏បានកក់ប្រាក់ថ្លៃទិញដីចំនួន ២០០.០០០$ (ម្ភៃម៉ឺន) ដុល្លាអាមេរិក ទៅឲ្យឈ្មោះ [redacted] មុនីរតន៍ ផងដែរ។

នៅថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៩ ខ្លួនបានប្រគល់ប្រាក់ថ្លៃដីចំនួន ៦៥០.០០០$ (ហុកសិបប្រាំម៉ឺន) ដុល្លាអាមេរិក ទៅឲ្យឈ្មោះ [redacted] មុនីរតន៍ បន្ថែមទៀតៗ បន្ទាប់មកនៅថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៩ ខ្លួនបានប្រគល់ប្រាក់ថ្លៃដីចំនួន ៨៥០.០០០$ (ប៉ែតសិបប្រាំម៉ឺន)ដុល្លាអាមេរិក ឲ្យទៅឈ្មោះ [redacted] មុនីរតន៍ បន្ថែមទៀតៗ ពេលនោះឈ្មោះ [redacted] មុនីរតន៍ និងបក្ខពួកបានយកឯកសារមួយចំនួនឲ្យនាងខ្ញុំផ្តិតមេដៃដោយបានប្រាប់ខ្លួនថា ជាលិខិតផ្ទេរសិទ្ធិដីធ្លីៗ ដោយសារឃើញការបញ្ជាក់ពីឈ្មោះ [redacted] មុនីរតន៍ និងបក្ខពួក ដូច្នេះខ្លួនរឹតតែមានទំនុកចិត្តទៅទៀតថាឈ្មោះ [redacted] មុនីរតន៍ ជាម្ចាស់កម្មសិទ្ធិនៃដី ហើយពិតជាអាចលក់ដីនេះមកឲ្យខ្លួនៗ

ក្រោយមកទៀតឈ្មោះ [redacted] មុនីរតន៍ និងឈ្មោះ [redacted] XIAOYU បានទាមទារប្រាក់ពីខ្លួនបន្ថែមទៀត ដោយបានបញ្ជាក់ថា យកទៅបង់ពន្ធប្រថាប់ត្រា ដើម្បីផ្ទេរកម្មសិទ្ធិ នៃដីមកខ្លួនឯដូច្នេះ ខ្លួនក៏បានប្រគល់ប្រាក់ចំនួន ៤០០.០០០$ (សែសិបម៉ឺន) ដុល្លាអាមេរិក ឲ្យទៅឈ្មោះ [redacted] មុនីរតន៍ បន្ថែមទៀត ពីព្រោះខ្លួនគិតថា ជួយសម្របសម្រួលដល់ឈ្មោះនេះ ដើម្បីធាប់បានដីមកគ្រប់គ្រង បើទោះបីជាកាលកំណត់បង់ប្រាក់មិនទាន់មកដល់ក៏ដោយណាមួយឈ្មោះ [redacted] XIAOYU ក៏បានបញ្ចុះបញ្ចូលខ្លួនផងដែរថា ឈ្មោះ [redacted] មុនីរតន៍ ខ្ចះប្រាក់យកទៅបង់ពន្ធដូច្នេះឈ្មោះ [redacted] XIAOYU បានពន្យល់ខ្លួនថា ឲ្យប្រគល់ប្រាក់ចំនួន ៤០០.០០០$ (សែសិបម៉ឺន)ដុល្លាអាមេរិក ទៅឲ្យឈ្មោះ [redacted] មុនីរតន៍ បន្ថែមទៀតមិនអីនោះទេៗ

សរុបទឹកប្រាក់ដែលខ្លួនបានប្រគល់ឲ្យឈ្មោះ [redacted] មុនីរតន៍ មានចំនួន ២.១០០.០០០$ (ពីរលានមួយសែន)ដុល្លាអាមេរិក ស្រាប់តែរដ្ឋបាលសាលាស្រុកបសេដ្ឋ បានចេញលិខិតលេខ ០៣២/២០ល.អ.ជ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២០ អញ្ជើញខ្លួនទៅចូលរួមក្នុងការសម្របសម្រួលលើករណី

ឈ្មោះ [redacted] មុនីរតន៍ មិនបានបង់ថ្លៃដីឲ្យប្រជាពលរដ្ឋម្ចាស់ដីដើមៗ ឃើញដូច្នេះ ខ្ញុំនពិតជាមានការតក់ស្លុតយ៉ាងខ្លាំង ហើយមិនអាចទទួលយកបាន ពីព្រោះថានាពេលកន្លងមកខ្ញុំនតែងតែជឿ និងទុកចិត្តលើឈ្មោះ [redacted] មុនីរតន៍ ថាជាម្ចាស់កម្មសិទ្ធិស្របច្បាប់ដី ប៉ុន្តែជាតុពិតខ្ញុំនទើបតែទទួលបានព័ត៌មានថា ដីទំហំ ៥៨ហិចតា ដែលឈ្មោះ [redacted] មុនីរតន៍ លក់ឲ្យខ្ញុំនជាដីកំពុងមានទំនាស់ និងជាដីរបស់ប្រជាពលរដ្ឋចំនួន ២ភូមិ គឺភូមិព្រៃរំដួលខាងត្បូង និងភូមិបឹងធ្នង់ ឃុំបសេដ្ឋ ស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ មិនមែនជាកម្មសិទ្ធិរបស់ឈ្មោះ [redacted] មុនីរតន៍ នោះឡើយ ។

រហូតមកដល់បច្ចុប្បន្ន រដ្ឋបាលសាលាស្រុកបសេដ្ឋ បានចេញលិខិតជូនដំណឹងស្តីពីការមោឃៈភាពលិខិតបទដ្ឋានគតិយុត្តិលេខ ០០៨/២០ សជណ ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២០ មានខ្លឹមសារថា រដ្ឋបាលសាលាស្រុក បានសម្រេចមោឃៈភាពលិខិតផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យមិនទាន់ចុះបញ្ជីលេខ ០៣២/២០ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០២០ និងលិខិតផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យមិនទាន់ចុះបញ្ជីលេខ ០៣៣/២០ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០២០ ដែលចេញដោយរដ្ឋបាលសាលាស្រុកបសេដ្ឋ អំពីការកាន់កាប់ដីចំនួន ១៧៨ ក្បាលស្មើនឹងទំហំ ៥៤៩.៤៨៣ (ប្រាំសែនបួនម៉ឺនប្រាំបួនពាន់បួនរយប៉ែតសិបបី) ម៉ែត្រក្រឡា ស្ថិតនៅភូមិព្រៃរំដួលខាងត្បូង និងភូមិបឹងធ្នង់ ឃុំបសេដ្ឋ ស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ របស់ប្រជាពលរដ្ឋចំនួន ១៤១គ្រួសារ ទៅឲ្យឈ្មោះ [redacted] មុនីរតន៍ ឃើញដូច្នេះ ទើបខ្ញុំនបានដឹងខ្លួនថា ខ្ញុំនបានចាញ់បោកឈ្មោះ [redacted] មុនីរតន៍ និងបក្ខពួកយ៉ាងពិតប្រាកដ ដោយឈ្មោះនេះមិនមានដីលក់ឲ្យខ្ញុំននោះឡើយ ហើយដីទំហំ ៥៨ហិចតា នេះគឺជាកម្មសិទ្ធិរបស់ប្រជាពលរដ្ឋស្ថិតនៅភូមិបឹងធ្នង់ និងភូមិព្រៃរំដួលខាងត្បូង ទេ ។

ចំពោះឈ្មោះ [redacted] ធីតា កេទស្រី គឺជាជំនួយការផ្ទាល់របស់ឈ្មោះ [redacted] មុនីរតន៍ ដែលឈ្មោះនេះតែងតែមកទទួលប្រាក់ពីខ្ញុំនជំនួសឲ្យឈ្មោះ [redacted] មុនីរតន៍។ នាពេលចុងក្រោយនេះឈ្មោះ [redacted] ធីតា តែងតែបញ្ចុះបញ្ចូលឲ្យខ្ញុំនប្រគល់ប្រាក់ថ្លៃដីដែលនៅសេសសល់ទាំងអស់ឲ្យឈ្មោះ [redacted] មុនីរតន៍ ពុំដូច្នោះទេ ប្រជាពលរដ្ឋនឹងយកដីនេះវិញ។ ខ្ញុំនមានការងឿងឆ្ងល់ទើបមិនទាន់ប្រគល់ប្រាក់ឲ្យទៅឈ្មោះ កែវ មុនីរតន៍ បន្តែម ។

ស្រាប់តែពេលក្រោយមកឃើញឈ្មោះ [redacted] ធីតា ទៅត្រូវរ៉ូវជាមួយប្រជាពលរដ្ឋម្ចាស់ដីដើមវិញ ទើបខ្ញុំនដឹងថាឈ្មោះ [redacted] ធីតា ជារចនាសម្ព័ន្ធឆបោករបស់ឈ្មោះ [redacted] មុនីរតន៍ ដែលដើរតួជាជំនួយការរបស់ឈ្មោះ [redacted] មុនីរតន៍ ផង ជាអ្នកសម្របសម្រួលរបស់ខ្ញុំន ផង និងជាអ្នកសម្របសម្រួលរបស់ប្រជាពលរដ្ឋម្ចាស់ដីផងៗ សកម្មភាពរបស់ឈ្មោះ [redacted] ធីតា គឺធ្វើឡើងក្នុងន័យបំភ័ន្តភ្នែកខ្ញុំនឲ្យបង់ប្រាក់ថ្លៃដីបន្តែមឲ្យឈ្មោះ [redacted] មុនីរតន៍ ប៉ុណ្ណោះ ទេ ។

ឈ្មោះ [redacted] XIAOYU និងឈ្មោះ [redacted] ធីតា បានឃុបឃិតគ្នាមកបោកប្រាស់ខ្ញុំនថា ឈ្មោះ [redacted] មុនីរតន៍ អស់ប្រាក់ហើយ និងមិនមានដីលក់ឲ្យខ្ញុំនទៀតទេ ជាពិសេសខ្ញុំនក៏មិនអាច

ប្តឹងផ្តល់ឈ្មោះ [redacted] មុនីរតន៍ បានដែរ ពីព្រោះឈ្មោះ [redacted] មុនីរតន៍ មានខ្សែធំណាស់ បន្ថែមពីលើនេះទៀតអ្នកទាំងពីរនាក់បានប្រាប់ខ្ញុំថា ត្រូវឲ្យប្រាក់ថ្លៃដីមកឲ្យពួកគេទាំងពីរនាក់ឲ្យបានចំនួន ១.៥០០.០០០$ (មួយលានហាសិបម៉ឺន) ដុល្លាអាមេរិក ដើម្បីឲ្យពួកគេធ្វើការទិញលក់ដីជំនួសឲ្យឈ្មោះ កែវ មុនីរនត៍ វិញ ។

ខ្ញុំនសំណូមពរសុំឲ្យតុលាការជួយរកយុត្តិធម៌ឲ្យខ្ញុំនផង ហើយខ្ញុំនសុំទាមទារប្រាក់ថ្លៃដីចំនួន ២.១០០.០០០$ (ពីរលានមួយសែន) ដុល្លាអាមេរិក ត្រឡប់មកវិញ និងទាមទារថ្លៃខូចខាតសំណងជម្ងឺចិត្តចំនួន ១.០៥០.០០០$ (មួយលានប្រាំម៉ឺន)ដុល្លាអាមេរិក និងបក្ខពួករបស់ឈ្មោះ [redacted] មុនីរនត៍ មកផ្តន្ទាទោសតាមច្បាប់។

-តាមអំណានចម្លើយសាក្សីឈ្មោះ [redacted] ធីតា បានឆ្លើយបំភ្លឺថា៖ ក្នុងរឿងនេះ នាងខ្ញុំមិនត្រូវអ្វី ជាមួយភាគីណានោះទេ ។

កាលពីអំឡុងខែកញ្ញា ឆ្នាំ២០១៩ នាងខ្ញុំបានចូលបម្រើការងារនៅក្រុមហ៊ុន កែវ សុខវាសនាវឌ្ឍនានាវតី ក្នុងមុខងារជាប្រធានផ្នែកទីផ្សារ (លក់ផ្ទះល្វែងនៅគីឡូ៣០ ផ្លូវលេខ៦១ ដោយទទួលបានប្រាក់ឈ្នួលចំនួន ១.០០០$ (មួយពាន់) ដុល្លាអាមេរិក ក្នុងមួយខែ ក្រោយមកលោកអគ្គនាយកឈ្មោះ [redacted] មុនីរតន៍ បានប្រាប់ថា មានចិនចង់ទិញដីនៅផ្លូវជាតិលេខ៦១ ស្ថិតក្នុងស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ និងប្រាប់ទៀតថា ជំនួយការរបស់គាត់ឈ្មោះ [redacted] សេង រ៉ាង បានកក់ដីប្រជាពលរដ្ឋមួយចំនួនហើយ គាត់បានប្រាប់ទៀតថាឈ្មោះ [redacted] សេង រ៉ាង ធ្វើកិច្ចការហ្នឹងមិនបានទេ ចេះតែមាន ភាពចម្រូងចម្រាស់រហូត ទើបគាត់ឲ្យនាងខ្ញុំចុះជួយការងារហ្នឹង។ ចំពោះដីដែលចុះទិញកក់ប្រជាពលរដ្ឋហ្នឹងមានទំហំប្រហែល ១០០$ (មួយរយដុល្លារអាមេរិក) ទៅ ៣០០$ (បីរយ) ដុល្លាអាមេរិក តែប៉ុណ្ណោះ ។ ចំពោះការប្រគល់ប្រាក់មកឲ្យនាងខ្ញុំ ដើម្បីយកទៅកក់ប្រជាពលរដ្ឋម្ចាស់ដីនោះ គឺលោកអគ្គនាយកឲ្យមកនាងខ្ញុំជាដំណាក់កាល។ ជាក់ស្តែងនាងខ្ញុំមានបញ្ជីប្រគល់ទទួលប្រាក់ ដែលមានចុះហត្ថលេខារបស់លោកអគ្គនាយកត្រឹមត្រូវ។ នៅក្នុងបញ្ជីនេះ នាងខ្ញុំបានបញ្ជាក់ច្បាស់ហើយ គឺចាប់ពីថ្ងៃទទួលប្រាក់លើកដំបូង គឺទទួលនៅកន្លែងណា វេលាម៉ោងប៉ុន្មាន ចំនួនលុយប៉ុន្មាន អីនោះទេ គឺនាងខ្ញុំដាក់ទាំងអស់ លុះពេលធ្វើការរួចហើយ ទើបនាងខ្ញុំប្រគល់ប្រាក់ដែលនៅសល់ឲ្យទៅលោកអគ្គនាយកវិញ ។ ចំពោះដីដូចដែលបានរៀបរាប់ខាងលើនេះ មានពិតប្រាកដមែន ពីព្រោះម្ចាស់ដីទាំងអស់បានមកទទួលប្រាក់កក់ថ្លៃដីពីនាងខ្ញុំដោយផ្ទាល់ ហើយម្យ៉ាងទៀតរាល់ឯកសារទាំងនោះ មានអាជ្ញាធរប្រថាប់ត្រាត្រឹមត្រូវទាំងអស់ ពុំមានឯកសារណាបន្លំបានឡើយ។ រហូតដល់អំឡុងខែធ្នូ ឆ្នាំ២០១៩ លោកអគ្គនាយកបានសំណូមពរសុំឲ្យអាជ្ញាធរជួយធ្វើការផ្ទេរសិទ្ធិកាន់កាប់ដីទាំងមូលទៅឲ្យលោកអគ្គនាយក ដោយសុំជំពាក់ប្រាក់សិន ចាំដល់ពេលផ្ទេរសិទ្ធិរួច លោកអគ្គនាយកនឹងបង់ប្រាក់កក់តាមក្រោយ។ ចំពោះសំណើនេះ អាជ្ញាធរមានការរារែក

ចិត្ត ពីព្រោះប្រជាពលរដ្ឋច្រើនគ្រួសារណាស់ (១៦៨ គ្រួសារ) ដូច្នេះហើយ ទាំងអាជ្ញាធរ និង តំណាងប្រជាពលរដ្ឋម្ចាស់ដី តម្រូវឲ្យលោក [redacted] មុនីរតន៍ ធ្វើលិខិតជានាអះអាងថា ប្រសិនបើមិន ចង់បង់ប្រាក់កក់ក្នុងរយៈពេល១០ថ្ងៃទេ ការផ្ទេរសិទ្ធិរវាង ប្រជាពលរដ្ឋម្ចាស់ដី និងលោក [redacted] មុនី រតន៍ ត្រូវចាត់ទុកជាមោឃៈ ហើយដាច់ប្រាក់កក់តែម្តងៗ ជាក់ស្តែងលោក [redacted] មុនីរតន៍ បានកុហក ប្រជាពលរដ្ឋ ក៏ដូចជាអាជ្ញាធរគ្រប់ជាន់ថ្នាក់ ដោយពុំបានបង់ប្រាក់បន្ត្រប់ការកក់ប្រាក់ថ្ងៃទិញដី ប្រជាពលរដ្ឋនោះឡើយ ជាហេតុបណ្តាលឲ្យប្រជាពលរដ្ឋខឹងខ្លាំងណាស់ អាជ្ញាធរក៏ខឹងដែរ ព្រោះ គាត់បានកុហកគេៗ

នាងខ្ញុំសុំបញ្ជូលឯកសារកសុតាងបញ្ជីទទួល និងចំណាយប្រាក់ ៣០០.០០០$ (សាមសិប ម៉ឺន)ដុល្លាអាមេរិក ដែលទទួលស្គាល់ដោយឈ្មោះ [redacted] មុនីរតន៍ និងតារាងសង្ខេបទឹកលុយសរុប ដែលបានចំណាយ ។

<u>សេចក្តីសន្និដ្ឋានរបស់តាគីបន្ទាប់ពីចប់ការសួរដេញដោល</u>

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានទោសថា: ក្រោយពីបានស្តាប់សួរដេញដោលនិង ពិនិត្យកសុតាងក្នុងសំណុំរឿង នាពេលសវនាការរួចមកឃើញថា: មានកសុតាង និងពិរុទ្ធភាពគ្រប់ គ្រាន់សម្រាប់ដាក់បន្ទុកទៅលើជនជាប់ចោទឈ្មោះ [redacted] មុនីរតន៍ ភេទប្រុស អាយុ៥៥ឆ្នាំ (មានសាវតា ជាតិ) ពីបទៈ **ឆបោកដោយមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅខេត្តកំពង់ស្ពឺ កាលពីអំឡុងឆ្នាំ២០១៩ ដល់អំឡុង ឆ្នាំ២០២០ បទល្មើសដែលមានចែង ឲ្យផ្តន្ទាទោសតាមមាត្រា **៣៧៧** និងមាត្រា ៣៨០ នៃក្រមព្រហ្មទណ្ឌ។ ដូច្នេះតំណាងអយ្យការនៅតែតម្កល់ដីកាសន្និដ្ឋានស្ថាពរទុកជាបានការពេញ ទាំងមូល សូមលោកចៅក្រមសម្រេចតាមច្បាប់ ។

.**សេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តីឲ្យដើមបណ្តឹងថា:** ក្រោយពីបានស្តាប់ចម្ងើយ និង អំ ណានចម្ងើយសាក្សី នាពេលសវនាការនេះរួចមកឃើញថា សុំរក្សាសេចក្តីសន្និដ្ឋានរបស់ការពារ សិទ្ធិ ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០២០ ទុកជាបានការដដែល ។

តាមអង្គហេតុ កាលពី អំឡុងឆ្នាំ២០១៩ ដល់អំឡុងឆ្នាំ២០២០ កូនក្តីខ្ញុំបាទបានចុះកិច្ចសន្យា លក់ទិញដី ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៩ របស់ឈ្មោះ [redacted] ម៉ឺងឈឺ (អ្នកទិញ) រវាង ឈ្មោះ [redacted] មុនីរតន៍ (អ្នកលក់) លើទំហំដីចំនួន ៥៨ ហិកតា មានទីតាំងស្ថិតនៅភូមិបឹងធ្នង់ និងភូមិព្រៃរំដួល ខាងត្បូង ឃុំបសេដ្ឋ ស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ តម្លៃចំនួន ៥,៨៦ $ (ប្រាំ ក្បៀស ប៉ែតសិប ប្រាំមួយ) ដុល្លាអាមេរិក ក្នុង ០១(មួយ) ម៉ែត្រការ៉េ ។ ឈ្មោះ [redacted] មុនីរតន៍ និង បក្ខពួក បានប្រើគ្រប់ មធ្យោបាយដើម្បីលួងលោមឲ្យកូនក្តីខ្ញុំបាទ ឈ្មោះ [redacted] ម៉ឺងឈឺ ធ្លាក់ក្នុងឧបាយកលទុច្ចរិត ហើយ បានចំណាយប្រាក់អស់ចំនួន ២.១០០.០០០$ (ពីរលានមួយសែន) ដុល្លាអាមេរិក ឲ្យទៅឈ្មោះ [redacted] មុនីរតន៍ ។ ដោយនៅមុនពេលទិញឈ្មោះ [redacted] មុនីរតន៍ .ឈ្មោះ [redacted] ជីតា និង ឈ្មោះ [redacted]

XIAOYU បានអះអាងយ៉ាងច្បាស់លាស់ថា ដីនេះជាកម្មសិទ្ធិរបស់ឈ្មោះ [redacted] មុនីរតន៍ ចុះហេតុអ្វីបានជាជាប់ពាក់ពន្ធ័ជាមួយប្រជាពលរដ្ឋទៅវិញ ។ ប៉ុន្តែរាល់សកម្មភាពទាំងនេះសុទ្ធតែជាល្បិចកលរបស់ឈ្មោះ [redacted] មុនីរតន៍ ដែលរួមគំនិតគ្នាជាមួយបក្ខពួករបស់ខ្លួនតែប៉ុណ្ណោះ។ តាមស្ថានភាពជាក់ស្តែងដីដែលជាកម្មវត្ថុនៃការទិញលក់ ដែលជាមិនមែនជាកម្មសិទ្ធិរបស់ឈ្មោះ [redacted] មុនីរតន៍ នោះឡើយ គឺជាកម្មសិទ្ធិរបស់ប្រជាពលរដ្ឋ ដែលជាម្ចាស់ដីចំនួន ០២ ភូមិប៉ុណ្ណោះ ។

ចំពោះឈ្មោះ [redacted] ធីតា ដែលជាសាក្សីមួយសំខាន់ ហើយក៏ជាបុគ្គលិករបស់ក្រុមហ៊ុន [redacted] មុនីរតន៍ ផងដែរ ។ ដោយកន្ទងមកឈ្មោះ [redacted] ធីតា នេះបានដើរតួសម្របសម្រួលគ្រប់ពេល ។ ហើយចម្ងើយរបស់ឈ្មោះ [redacted] មុនីរតន៍ ក្នុងដំណាក់កាលចៅក្រមសើបសួរ ក៏ទទួលស្គាល់ដែរ និងរកទិញដីឲ្យបានបង្គ្រប់ចំនួន៥៨ ហិកតា ដើម្បីលក់ទៅឲ្យឈ្មោះ [redacted] ម៉ីងឈឺ ។

តាមអង្គច្បាប់ អំពើ និង សកម្មភាពរបស់ឈ្មោះ [redacted] មុនីរតន៍ ដូចតំណាងអយ្យការបានធ្វើការចោទប្រកាន់ពីបទ: ឆបោក ដោយមានស្ថានទម្ងន់ទោស តាមបញ្ញត្តិមាត្រា ៣៧៧ . ៣៨០ នៃក្រមព្រហ្មទណ្ឌ ។

សំណូមពរ: តាមអង្គហេតុ និង អង្គច្បាប់ សុំឯកភាពតាមសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការទាំងស្រុង ។

.សុំផ្តន្ទាទោសឈ្មោះ [redacted] មុនីរតន៍ ព្រមទាំងចាប់ឃាត់ និង ឃុំខ្លួន តាមច្បាប់។

.បង្គាប់ឲ្យឈ្មោះ [redacted] មុនីរតន៍ ប្រគល់ប្រាក់ថ្លៃដី ចំនួន ២.១០០.០០០$ (ពីរលាន មួយសែន) ដុល្លាអាមេរិក មកឲ្យឈ្មោះ [redacted] ម៉ីងឈឺ វិញ ។

.សុំទាំទារសំណងជម្ងឺចិត្តជាប្រាក់ចំនួន ១.០៥០.០០០$ (មួយលាន ប្រាំម៉ឺន) ដុល្លាអាមេរិក

.**សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទថា:** ក្រោយពីបានស្តាប់ចម្ងើយ .ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ នាពេលសវនាការនេះរួចមកឃើញថា តាមអង្គហេតុកាលពី អំឡុងឆ្នាំ២០១៩ ដល់អំឡុងឆ្នាំ២០២០ កូនក្តីខ្ញុំបាទបានព្រមព្រៀងដូចនៅក្នុងកិច្ចសន្យា ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៩ របស់ឈ្មោះ [redacted] មុនីរតន៍ រវាងឈ្មោះហ្វក ម៉ីងឈឺ។

នោះយោងតាមមាត្រា ៣៧៧ នៃក្រមព្រហ្មទណ្ឌ តែក្នុងរឿងនេះវិញកូនក្តីខ្ញុំបាទពុំបានប្រព្រឹត្តដូចអ្វីការចោទប្រកាន់របស់តំណាងអយ្យការនោះទេ ។ ប៉ុន្តែប្រជាពលរដ្ឋទាំងនោះបានឲ្យកូនក្តីខ្ញុំមានសិទ្ធិក្នុងការលក់ដី ដែលបានទិញពីប្រជាពលរដ្ឋ ។ តែកូនក្តីខ្ញុំបាទពិតជាពុំទាន់បានទូទាត់ប្រាក់ទៅឲ្យប្រជាពលរដ្ឋ ទាំងនោះ ។

តាមមាត្រា ៣៨០ នៃក្រមព្រហ្មទណ្ឌ ដែលតំណាងអយ្យការចោទមកលើកូនក្តីខ្ញុំបាទ ដោយសុំបដិសេធចោលទាំងស្រុង ពាក្យថា ជាក្រុមដែលមានរចនាសម្ព័ន្ធ ចុះបញ្ជី ។

ដោយមានសេចក្តីណែនាំរួមមួយរបស់ក្រសួងយុត្តិធម៌ និង តុលាការកំពូល លេខ០៦ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០៥ ដែលចំណុចមិនឲ្យតុលាការអនុវត្តទៅលើកិច្ចសន្យា ទៅជាបទល្មើសឧបោក ទៅវិញ ។

ការដែលលោកមេធាវីការពារក្តីឲ្យដើមបណ្តឹង បានលើកឡើងនៃការខាតបង់នោះគឺមិនគោរពកាតព្វកិច្ច មាត្រា ៤០៨ . ៤០៩ នៃក្រមរដ្ឋប្បវេណី ដែលគ្មានព្យសន:កម្មឯណាទេទៅលើកូនក្តីរបស់លោក ដែលមានតែកូនក្តីខ្ញុំទេ រងនូវព្យសន:កម្មទាំងនោះ ។ ដោយសារមានបញ្ហាបែបនេះហើយទើបកូនក្តីខ្ញុំបាទបាត់បង់អតិថិជន សូមតុលាការពិចារណា។

ដោយពិនិត្យទៅលើជាតុផ្សំ <u>សត្យានុម័ត</u> ពិនិត្យទៅលើការទិញលក់ដីជាមួយប្រជាពលរដ្ឋគឺកូនក្តីខ្ញុំបានទិញតាំងពីដើមឆ្នាំ២០១៩ រហូតមកដល់ថ្ងៃទី០៥ , ០៧ ខែតុលា ឆ្នាំ២០១៩ លុះដល់ថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៩ ទើបកូនក្តីខ្ញុំបាទបានលក់ដីទៅឲ្យឈ្មោះ [redacted] ម៉ឺងឈឺ ។

ដោយពិនិត្យទៅលើជាតុផ្សំ <u>អត្តនោម័ត</u> កូនក្តីខ្ញុំបាទបានចុះកិច្ចសន្យាត្រឹមត្រូវតាមច្បាប់ ដោយគ្មានចេតនាទុច្ចរិតប្រព្រឹត្តបទល្មើសដូចការចោទប្រកាន់របស់តំណាងអយ្យការនោះទេ កូនក្តីខ្ញុំទេដែលរងនូវព្យសន:កម្មទាំងនោះ ។

កូនក្តីខ្ញុំបាទបានផ្ទេរសិទ្ធ ទៅឲ្យឈ្មោះ [redacted] ម៉ឺងឈឺ តាមលិខិតផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យដែលមិនទាន់ចុះបញ្ជីលេខ ០៣២ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៩ និងបានបង់ពន្ធត្រឹមត្រូវតាមច្បាប់ ។

ដោយផ្អែកទៅលើមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ និង មាត្រា ៣៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ (រាល់វិមតិសង្ស័យត្រូវបានផលប្រយោជន៍លើជនត្រូវចោទ) ហេតុនេះត្រូវសម្រេចឲ្យកូនក្តីខ្ញុំបាទរួចផុត ពីបទចោទប្រកាន់ចាប់ពីពេលនេះតទៅ និង សុំទាមទារសំណងចំនួន ៣.០០០.០០០$ (បីលាន) ដុល្លាអាមេរិក ។

សំដីចុងក្រោយរបស់ជនជាប់ចោទ:

-ឈ្មោះ [redacted] មុនីរតន៍ ស្នើសុំឲ្យតុលាការជួយលើកលែងការចោទប្រកាន់។

-ក្រោយពីបានស្តាប់ចម្ងើយជនជាប់ចោទ

-ក្រោយពីបានស្តាប់ចម្ងើយដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់អំណានចម្ងើយសាក្សី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តីឲ្យដើមបណ្តឹង

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តីឲ្យជនជាប់ចោទ

-ក្រោយពីបានពិនិត្យសំណុំរឿងឯកសារ និងកសុតាង

-ក្រោយពីបានធ្វើការពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

សាលាដំបូងខេត្តកំពង់ស្ពឺ

យល់ឃើញថា

-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] មុនីរតន៍ ប្រព្រឹត្តនៅខេត្តកំពង់ស្ពឺ កាលពីអំឡុងឆ្នាំ ២០១៩ រំលោភលើមាត្រា ៣៧៧ និងមាត្រា ៣៨០ នៃក្រមព្រហ្មទណ្ឌ គប្បីតុលាការលើកយកមកពិចារណាក្នុងការសម្រេចសេចក្តី ។

យល់ឃើញថា

-អំពើ និង សកម្មភាពរបស់ជនជាប់ចោទឈ្មោះ [redacted] មុនីរតន៍ បានប្រព្រឹត្តឡើងដោយចុះកិច្ចសន្យា លក់ទិញដី ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៩ របស់ឈ្មោះ [redacted] ម៉ីងឈឺ (អ្នកទិញ) រវាងឈ្មោះ [redacted] មុនីរតន៍ (អ្នកលក់) លើទំហំដីចំនួន ៥៨ ហិកតា មានទីតាំងស្ថិតនៅភូមិបឹងធ្នង់ និងភូមិព្រៃរំដួលខាងត្បូង ឃុំបសេដ្ឋ ស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ តម្លៃចំនួន ៥,៨៦ $ (ប្រាំ ក្បៀស ប៉ែតសិបប្រាំមួយ) ដុល្លាអាមេរិក ក្នុង ០១(មួយ) ម៉ែត្រការ៉េ ។ ដោយបានធ្វើសកម្មភាព ឆបោកទៅលើជនរងគ្រោះឈ្មោះ [redacted] ម៉ីងឈឺ (FU MINGQI) ដែលទង្វើរនេះធ្វើឲ្យប៉ះពាល់ដល់សន្តិសុខសណ្តាប់ធ្នាប់របៀបរៀបរយសាធារណៈក្នុងសង្គម ។ ជាក់ស្តែងជនជាប់ចោទបានទទួលប្រាក់ពីជនរងគ្រោះ ជាដំណាក់កាលសរុបទឹកប្រាក់ ចំនួន ២.១០០.០០០$ (ពីរលានដប់ម៉ឺន)ដុល្លាអាមេរិក ក្នុងការរៀបចំដី ដើម្បីលក់ទៅឲ្យជនរងគ្រោះ ។ លុះដល់ក្រោយមកទៀតទើបជនរងគ្រោះបានដឹងថាជនជាប់ចោទពុំមានដីលក់ឲ្យមកជនរងគ្រោះឡើយ ដោយដីទាំងនោះនៅជាកម្មសិទ្ធិរបស់ប្រជាពលរដ្ឋដដែលគឺឈ្មោះ [redacted] មុនីរតន៍ ពុំបានទូទាត់ប្រាក់ថ្លៃដីទៅឲ្យប្រជាពលរដ្ឋទាំងនោះទេ គប្បីតុលាការលើកយកអំពើនិងសកម្មភាពនេះមកធ្វើការពិនិត្យពិចារណាក្នុងការសម្រេចសេចក្តី។

យល់ឃើញថា

-ជនជាប់ចោទឈ្មោះ [redacted] មុនីរតន៍ ជាមនុស្សដែលមានការយល់ដឹងពុទ្ធិបានច្បាស់លាស់ជននេះនៅតែប្រព្រឹត្ត បង្ហាញឲ្យឃើញថានូវចេតនាទុច្ចរិតក្នុងអំពើឆបោក ហើយការបង្កហេតុនេះធ្វើឲ្យមានភាពចលាចលសង្គមដែលបានប្រើល្បិចធ្វើកិច្ចសន្យាជាអ្នកលក់ដី ទំហំចំនួន៥៨ ហិកតា ដើម្បីឲ្យជនរងគ្រោះឈ្មោះ [redacted] ម៉ីងឈឺ ផ្តល់ប្រាក់មកឲ្យខ្លួន នៅពេលបានប្រាក់ដល់ដៃហើយជនជាប់ចោទឈ្មោះ [redacted] មុនីរតន៍ មិនបានយកប្រាក់ទាំងនេះទៅទូទាត់ថ្លៃដីតាមកិច្ចសន្យានោះទេ បែរជាឲ្យប្រជាពលរដ្ឋនៅក្នុងភូមិបឹងធ្នង់ និងភូមិព្រៃរំដួលខាងត្បូង ស្ថិតក្នុងឃុំបសេដ្ឋ ស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ នាំគ្នាមកតវ៉ាពីរឿងទិញដី.លក់ដី មិនឲ្យប្រាក់គ្រប់ចំនួន ។ ដែលទង្វើរទាំងនេះហើយ ធ្វើឲ្យប្រជាពលរដ្ឋមានការមិនពេញចិត្តទៅនឹងជនជាប់ចោទឈ្មោះ [redacted] មុនីរតន៍ គប្បីតុលាការលើកយកមកពិចារណាក្នុងការសម្រេចសេចក្តី ។

យល់ឃើញថា

-តាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ម៉ីង់ឈី ([redacted] MINGQI) បានឆ្លើយថា: កាលពីអំឡុងឆ្នាំ២០១៩ ខ្ញុំនបានស្គាល់ឈ្មោះ [redacted] XIAOYU ភេទស្រី ជាជនជាតិចិន (សៀង ហៃ) ហើយឈ្មោះ[redacted] XIAOYU បាននិយាយប្រាប់ថាស្គាល់ឈ្មោះ [redacted] មុនីរតន៍ ជាអ្នកធំ និងជាអ្នកជំនួញអចលនទ្រព្យដ៏ធំក្នុងខេត្តកំពង់ស្ពឺ ក្រោយមកក៏មានការជួបគ្នារវាងឈ្មោះ [redacted] មុនីរតន៍ និងជំនួយការឈ្មោះ [redacted] ធីតា ជាមួយនឹងឈ្មោះ [redacted] ម៉ីង់ឈី ។ ហើយឈ្មោះ [redacted] មុនីរតន៍ បានអះអាង ថាគាត់មានដីដែលជាកម្មសិទ្ធិរបស់ខ្ញុំនស្របច្បាប់ចំនួន ៥៨ (ហាសិបប្រាំបី) ហិចតា ស្ថិតក្នុងភូមិព្រៃរំដួលខាងត្បូង និងភូមិបឹងធ្នង់ ឃុំបសេដ្ឋ ស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ ហើយឈ្មោះ [redacted] ម៉ីង់ឈី ក៏បានចុះកិច្ចសន្យាលក់ ទិញដី ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៩ ដោយបង់ប្រាក់ជាដំណាក់កាល។ លុះក្រោយមកទើបដឹងថា ដីដែលបានចុះកិច្ចសន្យាលក់ទិញនោះ គឺមិនមែនជាកម្មសិទ្ធិរបស់ឈ្មោះ [redacted] មុនីរតន៍ ឡើយ ហើយដីនោះក៏កំពុងមានបញ្ហាទំនាស់ជាមួយប្រជាពលរដ្ឋជាម្ចាស់កម្មសិទ្ធិ ពុំទាន់បានទទួលប្រាក់ថ្លៃដីគ្រប់ចំនួន គប្បីតុលាការលើកយកមកពិនិត្យពិចារណាក្នុងការសម្រេចសេចក្តី។

យល់ឃើញថា

.តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] មុនីរតន៍ ដែលថា ខ្ញុំនចុះកិច្ចសន្យាលក់-ទិញដីធ្លី ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៩ ជាមួយឈ្មោះ [redacted] ម៉ីង់ឈី ត្រឹមត្រូវតាមច្បាប់ ដោយមានដីពិតប្រាកដ តាមកិច្ចសន្យា ហើយប្រសិនបើ ឈ្មោះ [redacted] ម៉ីង់ឈី គាត់ប្រគល់ប្រាក់មកឲ្យខ្ញុំនគ្រប់ចំនួននោះ ខ្ញុំននឹងប្រគល់ដីឲ្យគ្រប់ចំនួនដែរ បើខ្ញុំនគ្មានដីឲ្យទេសុខចិត្តប្រគល់ឲ្យទៅឈ្មោះ [redacted] ម៉ីង់ឈី វិញគ្រប់ចំនួន ។ ហើយការបង្ហាញអំពីឆន្ទៈនេះគឺពុំមានកស្តុតាងណាមួយច្បាស់លាស់គប្បីតុលាការពិនិត្យពិចារណាក្នុងការសម្រេច។

យល់ឃើញថា

.តាមអំណានចម្លើយសាក្សីឈ្មោះ [redacted] ធីតា បានបញ្ជាក់ថា: ខ្ញុំនជាបុគ្គលិកឲ្យក្រុមហ៊ុនអចលនទ្រព្យ ដែលមានលោក [redacted] មុនីរតន៍ ជាអគ្គនាយក ។ ហើយក្នុងការលក់ដីឲ្យទៅឈ្មោះ [redacted] ម៉ីង់ឈី នោះខ្ញុំនបានដឹងដែរ ដោយខ្ញុំនជាអ្នកទូទាត់ប្រាក់កក់ថ្លៃដីផ្ទាល់ទៅឲ្យប្រជាពលរដ្ឋដែលជាម្ចាស់ដីដោយឈ្មោះ [redacted] មុនីរតន៍ បានប្រគល់ប្រាក់ឲ្យជាដំណាក់កាល មានបញ្ជីប្រគល់ទទួល ចុះហត្ថលេខាពីលោកអគ្គនាយកត្រឹមត្រូវ គប្បីតុលាការពិនិត្យពិចារណាសម្រេច។

យល់ឃើញថា

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានទោសនាពេលសវនាការថា នៅតែតម្កល់តាមដីកាសន្និដ្ឋានស្តាពរទុកជាបានការពេញទាំងមូល សូមតុលាការសម្រេចផ្តន្ទាទោសទៅតាមច្បាប់ គប្បីតុលាការពិនិត្យពិចារណាក្នុងការសម្រេច ។

យល់ឃើញថា

-មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់សម្រាប់ដាក់បន្ទុកទៅលើជនជាប់ចោទឈ្មោះ [redacted] មុនីរតន៍ ពីបទៈ ឆបោកដោយមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅខេត្តកំពង់ស្ពឺ កាលពីអំឡុងឆ្នាំ ២០១៩ ដល់អំឡុងឆ្នាំ២០២០ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ៣៧៧ និងមាត្រា ៣៨០ នៃក្រមព្រហ្មទណ្ឌ គប្បីតុលាការពិនិត្យពិចារណាសម្រេច ។

យល់ឃើញថា

.តាមសេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តីឲ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ម៉ឺងឈឺ បានលើកឡើងថា: កូនក្តីខ្លួនជាអ្នករងគ្រោះនូវអំពើ ឆបោក យ៉ាងធ្ងន់ធ្ងរ ដោយមិនមែនមានតែកូនក្តីខ្លួនតែម្នាក់ប៉ុណ្ណោះទេ គឺមានភាគហ៊ុនរបស់គាត់ ក្នុងការវិនិយោគទុនលើវិស័យអចលនទ្រព្យនៅស្រុកខ្មែរ គឺបានធ្វើឲ្យមានផលប៉ះពាល់ដល់ជីវភាពរបស់ប្រជាពលរដ្ឋរាប់ពាន់នាក់ ដែលរស់នៅក្នុងខេត្តកំពង់ស្ពឺ ប៉ុន្តែគោលបំណងនេះត្រូវបានរលាយទៅវិញដោយសារតែអំពើទុច្ចរិតរបស់ឈ្មោះ [redacted] មុនីរតន៍ និង បក្ខពួក ។ ហើយបានសំណូមពរតាមសេចក្តីសន្និដ្ឋានការពារសិទ្ធិចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០២០ ទុកជាបានការដដែល គប្បីតុលាការពិនិត្យពិចារណាក្នុងការសម្រេច។

យល់ឃើញថា

.តាមសេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] មុនីរតន៍ បានលើកឡើងថា: តាមអង្គហេតុ និង អង្គច្បាប់ ពុំមានជាតុផ្សំគ្រប់គ្រាន់សម្រាប់ដាក់បន្ទុកមកលើកូនក្តីខ្លួនដូចតំណាងអយ្យការចោទប្រកាន់នោះទេ បានស្នើសុំឲ្យតុលាការធ្វើការលើកលែងការចោទប្រកាន់មកលើកូនក្តីខ្លួន គប្បីតុលាការពិនិត្យពិចារណាក្នុងការសម្រេច ។

យល់ឃើញថា

.វត្ថុតាងដែលមាន ទូរសព្ទ័ដៃចំនួន០១គ្រឿង ម៉ាក HUAWEI MAT 30 PRO ពណ៌ស្នោត និង ស្រោមពណ៌ខ្មៅ ចំនួន ០១ ដកហូតពីជនជាប់ចោទឈ្មោះ [redacted] មុនីរតន៍ ដែលបានទទួលពីសមត្ថកិច្ច ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២០ របស់តំណាងអយ្យការ អមសាលាដំបូងខេត្តកំពង់ស្ពឺ ដោយវត្ថុតាងនេះពុំជាប់ពាក់ពន្ធ័ក្នុងបទល្មើសនេះ គប្បីតុលាការពិនិត្យពិចារណាក្នុងការសម្រេច ។

យល់ឃើញថា

.តាមការពិនិត្យអង្គហេតុនិងភស្តុតាង បានបង្ហាញឲ្យឃើញថា:បានព្រមព្រៀងគ្នាផ្តើមចេញពីកិច្ចសន្យាលក់-ទិញដីធ្លី ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៩ របស់ឈ្មោះ [redacted] មុនីរតន៍ (អ្នកលក់)

រវាងឈ្មោះ [redacted] ម៉ឺងឈឺ (អ្នកទិញ) ក្នុងទំហំចំនួន ៥៨ ហិកតា មានទីតាំងស្ថិតនៅភូមិបឹងធ្នង់ និង ភូមិព្រៃរំដួលខាងត្បូង ឃុំបសេដ្ឋ ស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ តម្លៃចំនួន ៥,៨៦ $ (ប្រាំ ក្បៀស ប៉ែតសិបប្រាំមួយ) ដុល្លាអាមេរិក ក្នុង ០១ (មួយ) ម៉ែត្រការ៉េ ។ ក្រោយពីចុះកិច្ចសន្យារួចមកឃើញថា ភាគីអ្នកលក់ បានទទួលប្រាក់កក់ ពីអ្នកទិញ បាន០២ដំណាក់កាល សរុបចំនួន ២.១០០.០០០$ (ពីរលានដប់ម៉ឺន) ដុល្លាអាមេរិក។ នៅក្នុងដំណាក់កាលទី៣ នេះដែលត្រូវធ្វើការទូទាត់គ្នានឹងប្រគល់ប្លង់ដីដែលបានកាត់ផ្ទេរឈ្មោះ ពីប្រជាពលរដ្ឋ រួចរាល់ត្រឹមត្រូវតាមច្បាប់ទៅឲ្យឈ្មោះ [redacted] ម៉ឺងឈឺ ។ ក្រោយមកទើបតែឈ្មោះ [redacted] ម៉ឺងឈឺ បានដឹងថាឈ្មោះ [redacted] មុនីរតន៍ ពុំមានដីពិតប្រាកដនោះទេ ។ ដោយប្រជាពលរដ្ឋទាំងនោះបានប្រាប់ថា លុះត្រាតែប្រគល់ប្រាក់គ្រប់ចំនួនទើបប្រជាពលរដ្ឋជាម្ចាស់ដីដើមយល់ព្រមផ្ទេរសិទ្ធិកម្មសិទ្ធិនៃដីទាំងអស់នោះឲ្យទៅ ឈ្មោះ [redacted] ម៉ឺងឈឺ ប្រសិនបើមិនប្រគល់ប្រាក់គ្រប់ចំនួនទេ ប្រជាពលរដ្ឋនឹងយកដីនោះវិញហើយ គប្បីតុលាការពិនិត្យពិចារណាក្នុងការសម្រេច ។

<u>យល់ឃើញថា</u>

.តាមអង្គហេតុនៃរឿងក្តីនេះ បានបញ្ជាក់ឲ្យឃើញថា គឺជាវិវាទដែលកើតចេញពីការមិនអនុវត្តកាតព្វកិច្ចឲ្យបានពេញលេញនូវកិច្ចសន្យាទិញ-លក់ដីធ្លី ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៩ ដោយចំណុចវិវាទទាំងនេះហើយត្រង់ចំណុចអនុវត្តកាតព្វកិច្ចនៃកិច្ចសន្យាទាក់ទងទៅនឹងការ បង់ប្រាក់ក្នុងដំណាក់កាលទី៣ ដែលមានភាពស្របគ្នាទៅនឹង ប្រការ ៣ . (៤) នៃកិច្ចសន្យា បង់ប្រាក់លើកទី៣ ជូនទៅភាគី (ក) ជាអ្នកលក់ ក្នុងរយៈពេល០១(មួយ)ខែ បន្ទាប់ពីបង់ពន្ធ និងបំពេញបែបបទចប់លើលិខិតផ្ទេរសិទ្ធិកាន់កាប់អចលនវត្ថុ ដែលមិនទាន់ចុះបញ្ជី នៅសាលាស្រុកបសេដ្ឋ ដូចនេះគូភាគីពុំទាន់បានទូទាត់ប្រាក់គ្រប់ថ្លៃដីទៅតាមកិច្ចសន្យានៅឡើយទេ ដោយនៅពេលនេះតុលាការពុំបានលើកយកកស្តុតាង និង ពិនិត្យកស្តុតាងនានាឲ្យបានច្បាស់លាស់នៅក្នុងការបំពេញកាតព្វកិច្ចទៅតាមកិច្ចសន្យានោះទេ គប្បីតុលាការទុកសិទ្ធិឲ្យគូភាគីដាក់បណ្តឹងទាមទារប្រាក់ទូទាត់ថ្លៃដី ទៅតុលាការរដ្ឋប្បវេណី ដើម្បីចាត់ការតាមច្បាប់ ។

<u>យល់ឃើញថា</u>

-សំដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] មុនីរតន៍ សុំឲ្យតុលាការធ្វើការលើកលែងចោទប្រកាន់លើរូបខ្លួន គប្បីតុលាការពិនិត្យពិចារណាក្នុងការសម្រេច។

សាលាដំបូងខេត្តកំពង់ស្ពឺ

<u>វិនិច្ឆ័យសេចក្តី</u>

<u>១/ ផ្តន្ទាទោសលើជនជាប់ចោទ:</u>

-ឈ្មោះ [redacted] **មុនីរតន៍** ភេទប្រុស អាយុ ៥៩ឆ្នាំ ជនជាតិខ្មែរ (មានសាវតាជាតិខាងលើ) ជាក់ពន្ធនាគារកំណត់រយៈពេលចំនួន **០២(ពីរ)ឆ្នាំ** តែទោសអនុវត្តក្នុងពន្ធនាគារកំណត់ចំនួន **០៥**

(ប្រាំ)ខែ និង ០៦(ប្រាំមួយ) ថ្ងៃ ទោសនេះត្រូវបានអនុវត្តរួចហើយក្នុងរយៈពេលនៃការឃុំខ្លួនជាបណ្តោះអាសន្ន ឯទោសនៅសល់ព្យួរធម្មតា ។

ពីរបទៈ ឧបោកដោយមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅភូមិបឹងធ្នង់ និង ភូមិព្រៃរំដួលខាងត្បូង ស្ថិតក្នុងឃុំបសេដ្ឋ ស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ កាលពីអំឡុងឆ្នាំ២០១៩ ដល់អំឡុងឆ្នាំ២០២០ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ៣៧៧ , ៣៨០ និង មាត្រា ១០៨ នៃក្រមព្រហ្មទណ្ឌ ។

២./ វត្ថុតាងមានៈ

.ទូរសព្ទ័ដៃចំនួន០១ (មួយ) គ្រឿង ម៉ាក HUAWEI MAT 30 PRO ពណ៌ស្នោត និង ស្រោមពណ៌ខ្មៅ ចំនួន ០១ (មួយ) ត្រូវប្រគល់ឲ្យទៅម្ចាស់ដើមវិញ ។

៣./បង្គាប់ឲ្យជនជាប់ចោទឈ្មោះ [redacted] **មុនីរតន៍** បង់សងសំណងជម្ងឺចិត្ត ថ្លៃខាតបង់ពេលវេលាជាប្រាក់ចំនួន ២០០.០០០.០០០រ (ពីររយលាន) រៀល ឲ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ម៉ីឆឃឺ** ។

៤./ទុកសិទ្ធិឲ្យគូភាគីឈ្មោះ [redacted] **ម៉ីឆឃឺ** រវាងឈ្មោះ [redacted] **មុនីរតន៍** ប្តឹងទាមទារប្រាក់ទៅតុលាការរដ្ឋប្បវេណី តាមច្បាប់។

៥./សាលក្រមនេះជំនុំជម្រះ នៅថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០២០ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] មុនីរតន៍ ដែលមានលោក [redacted] សុផល ជាមេធាវី , ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ម៉ីឆឃឺ ដែលមានលោក យូ លីមហួត ជាមេធាវី និង ប្រកាសជាសាធារណៈនៅថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២១។

-ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

ក្រឡាបញ្ជី

[redacted]

ចៅក្រមជំនុំជម្រះ